**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ :**......០០៣/២០.............**ក.ប/ស.ជ.ណ.ព.ទ.ក**

*ថ្ងៃព្រហស្បតិ៍ ៥រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣*

*រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ២០២០*

# សេចក្តីជូនដំណឹង

យោងតាមអនុក្រឹត្យលេខ ១៥០ អនក្រ.បក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៧ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សិស្ស និស្សិត យុវជន មាតាបិតា អាណាព្យាបាល សាធារណជន និងសហគ្រាស គ្រឹះស្ថាន ឧស្សាហកម្ម ក្រុមហ៊ុនឯកជន អង្គការជាតិ និងអន្តរជាតិ មេត្តាជ្រាបថា ក្រសួងនឹងរៀបចំ "ទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ លើកទី៣ ឆ្នាំ២០២០" នៅអគារពិព័រណ៍ពាណិជ្ជកម្មកោះពេជ្រ A-F ដែលមានរយៈពេលពីរថ្ងៃ គឺចាប់ពីថ្ងៃចន្ទ ១០រោច ដល់ថ្ងៃអង្គារ ១១រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី១៥ ដល់ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០ ចាប់ពីម៉ោង ៨:០០ នាទី ព្រឹក ដល់ម៉ោង ៨:០០ នាទី យប់។ ទិវាជាតិនេះ មានសារៈសំខាន់ណាស់សម្រាប់ប្អូនៗសិស្ស និស្សិត យុវជនដែលកំពុងតែត្រៀមខ្លួនចូលទៅកាន់ទីផ្សារការងារនាពេលខាងមុខ ដើម្បីទទួលបាននូវព័ត៌មានពីតម្រូវការទីផ្សារការងារក្នុងពេលបច្ចុប្បន្ន និងទៅអនាគត សម្រាប់ជាមូលដ្ឋានគ្រឹះក្នុងការសម្រេចចិត្តជ្រើសរើសជំនាញមកសិក្សា។ លើសពីនេះទៅទៀត គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ក្រោមឱវាទក្រសួងនឹងធ្វើការណែនាំលើមុខជំនាញបច្ចេកទេសដែលខ្លួនកំពុងធ្វើការបណ្តុះបណ្តាល តាមរយៈការដាក់តាំងបង្ហាញស្នាដៃសិស្ស និស្សិត ដែលបានអនុវត្តកន្លងមក និងផ្នែកឯកជន ក៏បានចូលរួមដាក់បង្ហាញពីខ្សែសង្វាក់ផលិតកម្ម និងពីតម្រូវការកម្លាំងពលកម្មជំនាញដែលទីផ្សារការងារកំពុងត្រូវការនាពេលបច្ចុប្បន្ន និងទៅអនាគត។

ព័ត៌មានលម្អិតសូមធ្វើការទំនាក់ទំនងមកកាន់ នាយកដ្ឋានព័ត៌មានទីផ្សារការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលមានអាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឬតាមរយៈលេខទូរស័ព្ទ៖ ០៦១ ៧៧៧ ៦៣៧/០១៧ ៧៤៧ ៧៧៣/០១០ ៣០៦ ៨៥៥/០៩៨ ៩៨៧ ៧៧៩/០១២ ២២៣ ១៨៩ ឬអ៊ីម៉ែល៖ pisey_ange@ymail.com/kimravuth@gmail.com។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសិស្ស និស្សិត យុវជន មាតាបិតា អាណាព្យាបាល សាធារណជន និងអង្គភាពពាក់ព័ន្ធទាំងអស់ មេត្តាជ្រាបជាព័ត៌មាន និងអញ្ជើញចូលរួមឲ្យបានច្រើនកុះករ។

រដ្ឋមន្ត្រី

**អ៊ិត សំហេង**

**ចម្លងជូន៖**

- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត និងអង្គភាពពាក់ព័ន្ធ
- គ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈរាជធានី ខេត្ត
  *"ដើម្បីផ្សព្វផ្សាយ"*
- ឯកសារ-កាលប្បវត្តិ